ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តមណ្ឌលគិរី
សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៩
ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩
សាលក្រមព្រហ្មទណ្ឌ
លេខ ...២២៧.../២១ "ឃ"
ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តមណ្ឌលគិរី

បានបើកសវនាការជាសាធារណៈ នាថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តមណ្ឌលគិរី

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តមណ្ឌលគិរី

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តមណ្ឌលគិរី

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៩ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្តឹងមកតុលាការតាមដីកាដំណោះស្រាយលេខ ២២១១/២០ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តមណ្ឌលគិរី មានជនជាប់ចោទឈ្មោះ [redacted] ស្រីនុច ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ មុខរបរមេផ្ទះ ទីកន្លែងកំណើតនៅ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ឪពុកឈ្មោះ [redacted] ភីម "ស្លាប់" ម្តាយឈ្មោះ [redacted] គីមទៀង "ស្លាប់" ប្តីឈ្មោះ [redacted] ដារ៉ា មានកូន ចំនួន ០៤នាក់ ប្រវត្តិផ្តន្ទាទោសដោយតុលាការ "គ្មាន"។ (ក្រៅឃុំ)

ជាប់ចោទពីបទ៖ លួចលក់អចលនវត្ថុរបស់អ្នកដទៃ និងបទ សុំឱ្យផ្តល់ឯកសារដោយទុច្ចរិត ប្រព្រឹត្តនៅសង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៥៥ នៃច្បាប់ភូមិបាល និងមាត្រា៦៣២ នៃក្រមព្រហ្មទណ្ឌ។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ លោកស្រីមេធាវី [redacted]។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ ភេទស្រី អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិឡៅកា សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។



Scanned with CamScanner

មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី លោកមេធាវី [redacted]

- មេធាវី [redacted]។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៧៩ អ.យ.ត/២០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០។

- បានឃើញ ដីកាដំណោះស្រាយលេខ ២២១១/២០ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០។

- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៤១៦ រប/២១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

- បានឃើញ ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ១៣៦៣/២១ ចុះថ្ងៃ២៤ ខែវិច្ឆិកា ឆ្នាំ២០២១។

## អង្គហេតុដែលឡើងមកតុលាការ[1]

កាលពីអំឡុងឆ្នាំ២០១៥ ឈ្មោះ[redacted] ស្រីនុច បានផ្ទេរកម្មសិទ្ធិលើដីមួយកន្លែង ដែលមានទីតាំងស្ថិតនៅភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ទៅឱ្យឈ្មោះ[redacted] មុំ ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ០៥៩/១៥ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ចុះហត្ថលេខាដោយមេឃុំឈ្មោះ[redacted] គ្រើន និងមេភូមិពូត្រុំ។ នៅអំឡុងឆ្នាំ២០១៨ ឈ្មោះ [redacted] ស្រីនុច បានលក់ដីខាងលើដដែលនេះឱ្យទៅឈ្មោះ [redacted] និងបានទៅនិយាយភូតកុហកអាជ្ញាធរសង្កាត់រមនាថា ផ្ទះរបស់ខ្លួនដែលស្ថិតក្នុងផ្សារសែនមនោរម្យ ត្រូវបានភ្លើងឆេះ រួមទាំងឯកសារដីធ្លីផ្សេងៗទាំងអស់ ហើយបានស្នើសុំឱ្យអាជ្ញាធរចេញលិខិតផ្ទេរសិទ្ធកាន់កាប់ដីធ្លី ឱ្យទៅឈ្មោះ ថាត។ រហូតដល់ឆ្នាំ២០១៩ ទើបឈ្មោះ[redacted] មុំ បានដឹងថាឈ្មោះ [redacted] ស្រីនុច បានលក់ និងផ្ទេរសិទ្ធិលើដីដែលជាកម្មសិទ្ធិរបស់ខ្លួនទៅឱ្យអ្នកដទៃ។

## នារពលសទនាការ

- ជនជាប់ចោទឈ្មោះ [redacted] ស្រីនុច ឆ្លើយថា៖ ខ្លួនទទួលស្គាល់លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ០៥៩/១៥ ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៥ ហើយស្នាមមេដៃនេះ ពិតជារបស់ខ្លួនប្រាកដមែន ប៉ុន្តែលិខិតផ្ទេរសិទ្ធិនេះមិនមែនកើតចេញពីការលក់-ទិញនោះទេ គឺពេលនោះខ្លួនមានបំណងខ្ចីប្រាក់ពីធនាគារ ប៉ុន្តែមិនអាចខ្ចីបាន ព្រោះខ្លួនធ្លាប់ខ្ចីធនាគារពុំទាន់សងអស់ ទើបខ្លួនទៅពិភាក្សាជាមួយឈ្មោះ [redacted] មុំ ឱ្យទៅជួយខ្ចីធនាគារ រួចហើយខ្លួនក៏ធ្វើលិខិតផ្ទេរកម្មសិទ្ធិដីធ្លីខាងលើឱ្យឈ្មោះ [redacted] មុំ តែម្ដង។ ក្រោយពេលធ្វើលិខិតផ្ទេរសិទ្ធិរួចហើយ ខ្លួន និងឈ្មោះ [redacted] មុំ ទៅខ្ចីលុយនៅធនាគារ ប៉ុន្តែគេមិនទទួលនោះទេ ដោយសារលិខិតនេះខ្វះស្នាមមេដៃសាក្សី។ លិខិតនេះត្រូវបានឈ្មោះ [redacted] មុំ រក្សាទុករហូត ខ្លួនក៏ពុំបានខ្វាយខ្វល់នោះទេ ព្រោះគិតថាពុំគ្រប់លក្ខខណ្ឌ ម្យ៉ាងវិញទៀត ដោយសារទុកចិត្តឈ្មោះ[redacted] មុំ។ ក្រោយពីធ្វើលិខិតនេះរួច ខ្លួនពុំធ្លាប់ឃើញឈ្មោះ[redacted] មុំ ទៅកាន់កាប់ដីនោះទេ ហើយខ្លួនក៏ពុំបានទៅកាន់កាប់នោះដែរ គឺទុកចោល ។ នៅឆ្នាំ២០១៨ ខ្លួនបានលក់ដីនេះឱ្យទៅឈ្មោះ ថាត ភេទប្រុស រស់នៅភ្នំពេញ ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់មានឈ្មោះ រិន ធ្វើការនៅសាលាឃុំ ជាអ្នករត់ការ។ ខ្លួនស្រពិចស្រពិល មិនច្បាស់ថាខ្លួនបានប្រាប់ឈ្មោះ រិន ឬអាជ្ញាធរសង្កាត់រមនា អំពីឯកសារបញ្ជាក់កម្មសិទ្ធិដី នៅពេលផ្ទេរសិទ្ធិឱ្យឈ្មោះ ថាត ឬយ៉ាងណាទេ។ នៅពេលធ្វើលិខិតផ្ទេរសិទ្ធិខ្លួនបានភ្ជាប់

---

[1] មាត្រា ៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ឯកសារប្លង់ចាស់ ដែលបានទិញពីឈ្មោះ លី ហេង។ ខ្លួនក៏មិនបានប្រាប់អាជ្ញាធរថាខ្លួនធ្លាប់ផ្ទេរសិទ្ធិកាន់កាប់ដីធ្លីឱ្យឈ្មោះ [redacted] មុំ នោះទេ ព្រោះគិតថាឯកសារនោះខ្វះលក្ខខណ្ឌគ្រប់គ្រាន់ (ខ្វះសាក្សី និងមេដៃត្រំ) ហើយអាជ្ញាធរមិនបានសួរនាំផងដែរ។

- សាក្សីឈ្មោះ [redacted] ង្វូក ឆ្លើយថា៖ នៅឆ្នាំ២០១៨ ពេលភ្លើងឆេះផ្សារ ហើយប្រហែលមួយខែ ឈ្មោះ [redacted] ស្រីនុច បានមកសុំធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ដោយឈ្មោះ [redacted] ស្រីនុច ប្រាប់ថាភ្លើងឆេះផ្ទះ និងឯកសារអស់ហើយ។ ពេលនោះខ្លួនបានឱ្យក្មេងៗទៅពិនិត្យទីតាំងដីរបស់ឈ្មោះ [redacted] ស្រីនុច ហើយលោកមេភូមិឈ្មោះ [redacted] សាមិត បានបញ្ជាក់ថា ពិតជាដីរបស់ឈ្មោះ [redacted] ស្រីនុច ពិតប្រាកដមែន។ ឈ្មោះ [redacted] ស្រីនុច កាន់ឯកសារមកជាមួយឈ្មោះ [redacted] ធីល និងឈ្មោះ [redacted] ណារិន ដើម្បីសុំធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី។ នៅពេលប្រជាជនណាមកសុំធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ គឺខ្លួនឱ្យកូនចៅចុះទៅពិនិត្យដល់ទីតាំង និងឱ្យស្មៀនពិនិត្យមើលនៅក្នុងគល់បញ្ជី សៀវភៅធំ សម្រាប់ចុះលេខចេញ-ចូល ហើយសៀវភៅដីធ្លីនេះ ត្រូវបានរក្សាទុកដោយស្មៀន។ លុះដល់ឆ្នាំ២០១៥ សៀវភៅដីធ្លីនេះបានបាត់ ហើយនៅឆ្នាំ២០១៦ ខ្លួនក៏បានទៅប្រាប់ដោយផ្ទាល់មាត់ នៅសាលាក្រុងសែនមនោរម្យ (ច្រកចេញ-ចូល និងរដ្ឋបាល) អំពីការបាត់សៀវភៅដីធ្លីក្នុងឆ្នាំ២០១៥ និងបានធ្វើសេចក្តីបិទប្រកាសនៅសង្កាត់រមនា។ ចំពោះសៀវភៅដីធ្លី២០១៨ និងឯកសារពាក់ពន្ធ័ឈ្មោះ [redacted] ស្រីនុច គឺមានការរក្សាទុកនៅសង្កាត់រមនា ប៉ុន្តែមិនមានព័ត៌មានពាក់ពន្ធ័នឹងឈ្មោះ [redacted] ស្រីនុច ផ្ទេរសិទ្ធិទៅឱ្យអ្នកណានោះទេ ហើយខ្លួនក៏រកមិនឃើញដែរ។ ពេលឈ្មោះ [redacted] ស្រីនុច ធ្វើលិខិតទិញ-លក់ គឺបានផ្តិតមេដៃចំពោះមុខខ្លួនតែម្នាក់ឯង មិនឃើញមានវត្តមានប្តីរបស់ឈ្មោះ [redacted] ស្រីនុច នោះទេ និងមិនមានស្នាមមេដៃរបស់អ្នកទិញដែរ ព្រោះឈ្មោះ [redacted] ស្រីនុច ប្រាប់ខ្លួនថា ខ្វះឯកសាររបស់អ្នកទិញសិន នៅពេលដែលអ្នកទិញឱ្យលុយគ្រប់ចំនួនចាំមកផ្តិតមេដៃរបស់អ្នកទិញ។

- សាក្សីឈ្មោះ [redacted] ធីល ឆ្លើយថា៖ ឈ្មោះ [redacted] ស្រីនុច មានផ្ទះនៅក្នុងផ្សារ ក្រោយភ្លើងឆេះផ្សារ ក្នុងឆ្នាំ២០១៨ គាត់មកជួបខ្លួនសុំឱ្យធ្វើឯកសារផ្ទេរសិទ្ធិកាន់កាប់ ដោយឈ្មោះ [redacted] ស្រីនុច មកប្រាប់ខ្លួនថា ភ្លើងឆេះឯកសារអស់។ ឈ្មោះ [redacted] ស្រីនុច បានបំពេញឯកសាររួចរាល់ (ទម្រង់) មកជួបខ្លួន ដើម្បីជួយឱ្យចេញលិខិតផ្ទេរសិទ្ធិដីធ្លីលក់ដីនៅភូមិពូត្រុំ ប៉ុន្តែខ្លួនបានឱ្យទៅជួបលោក [redacted] ណារិន លោកចៅសង្កាត់ និងជំនួយការរដ្ឋបាលសង្កាត់ ដើម្បីធ្វើកិច្ចការនេះ។ បន្ទាប់មកលោក [redacted] ណារិន បានចុះពិនិត្យទីតាំងដីជាមួយឈ្មោះ [redacted] ស្រីនុច និងលោកមេភូមិពូត្រុំ។ មួយសប្តាហ៍ក្រោយមក ទើបខ្លួនឃើញថាឯកសាររបស់ឈ្មោះ [redacted] ស្រីមុច ធ្វើរួចរាល់ ដោយខ្លួនមិនបានចុះលេខនោះទេ គឺមន្ត្រីរដ្ឋបាលជាអ្នកចុះ។ ខ្លួនធ្វើជាស្មៀនតាំងពីលោកចៅសង្កាត់រមនាចាស់នៅរស់ ហើយខ្លួនមិនធ្លាប់ឃើញលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីរវាងឈ្មោះ [redacted] ស្រីនុច និងឈ្មោះ [redacted] មុំ នោះទេ។ ខ្លួនសូមបញ្ជាក់ថា ហត្ថលេខាក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់រវាងឈ្មោះ [redacted] ស្រីនុច និងឈ្មោះ [redacted] មុំ គឺហត្ថលេខារបស់លោកចៅសង្កាត់ [redacted] ត្រើន។ សៀវភៅដីធ្លីក្នុងឆ្នាំ២០១៥ បានបាត់ហើយ។ នៅពេល

ឈ្មោះ [redacted] ស្រីនុច មកសុំឯកសារ មិនមានឯកសារតម្កល់នៅក្នុងសង្កាត់នោះទ ដោយធ្វើតែមួយច្បាប់។ ខ្លួនមិនបានធ្វើផ្ទាល់ដៃនោះទេ គឺរដ្ឋបាលជាអ្នកធ្វើ។ ឈ្មោះ [redacted] ស្រីនុច កាន់ឯកសារមកតែម្នាក់ឯង។

- សាក្សីឈ្មោះ [redacted] ណារិន ឆ្លើយថា៖ នៅក្នុងឆ្នាំ២០១៨ ពេលឈ្មោះ [redacted] ស្រីនុច មកសុំឱ្យធ្វើឯកសារ គឺពេលនោះស្មៀនសង្កាត់រមនា ([redacted] ធីល) បានឱ្យឯកសារដែលពាក់ពន្ធ័នឹងឈ្មោះ [redacted] ស្រីនុច មកឱ្យខ្លួនជួយធ្វើកិច្ចការជំនួសគាត់ រួចហើយខ្លួនបានចុះទៅពិនិត្យទីតាំងដី ជាមួយឈ្មោះ [redacted] ស្រីនុច ដោយឈ្មោះ [redacted] ស្រីនុច បានចង្អុលទីតាំងដី រួចហើយពេលរសៀលទើបខ្លួនបានជួបនឹងលោកមេភូមិព្ធត្រុំ ព្រមទាំងលោកមេភូមិបានចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិកាន់កាប់ពីឈ្មោះ [redacted] ស្រីនុច ទៅអ្នកថ្មី(មិនចាំ)។ ក្រោយពីធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់រួចហើយ ខ្លួនទាក់ទងទៅឈ្មោះ [redacted] ស្រីនុច ប៉ុន្តែទាក់ទងមិនបាន។ ចំពោះឯកសាររបស់ឈ្មោះ [redacted] ស្រីនុច គឺធ្វើនៅឆ្នាំ២០១៨ ប៉ុន្តែចុះថ្ងៃខែឆ្នាំក្នុងឆ្នាំ២០១៦ មូលហេតុដើម្បីគេចពន្ធ។ ខ្លួនមិនច្បាស់ថាយកលេខក្នុងឆ្នាំ២០១៦ ឬឆ្នាំ២០១៨ ដែរ។

- សាក្សីឈ្មោះ [redacted] សាមិត ឆ្លើយថា៖ ខ្លួនដឹងថាឈ្មោះ [redacted] ស្រីនុច បានផ្ទេរសិទ្ធិកាន់កាប់ដីទៅឱ្យឈ្មោះ ឯក មុំ ដោយធ្វើនៅផ្ទះរបស់ខ្លួន។ ពេលនោះឈ្មោះ [redacted] ស្រីនុច បានកាន់លិខិតផ្ទេរសិទ្ធរវាងឈ្មោះ ញឹម ស្រីនុច និងឈ្មោះ [redacted] ហេង ទើបខ្លួនធ្វើលិខិតផ្ទេរសិទ្ធកាន់កាប់ដីថ្មីពីឈ្មោះ [redacted] ស្រីនុច ទៅឱ្យឈ្មោះ [redacted] មុំ ដោយខ្លួនជាអ្នកសរសេរផ្ទាល់ដៃ។ ខ្លួនពិតជាបានចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិរវាងឈ្មោះ [redacted] ស្រីនុច និងឈ្មោះ [redacted] ថាត នោះពិតមែន ដោយបានធ្វើនៅផ្ទះរបស់ខ្លួន។ លិខិតផ្ទេរសិទ្ធនេះ គឺឈ្មោះ [redacted] ស្រីនុច និងឈ្មោះ [redacted] ណារិន ជាអ្នកកាន់ទៅឱ្យខ្លួនចុះហត្ថលេខា ដោយមិនបានភ្ជាប់ជាមួយនឹងលិខិត ទិញលក់ដើមនោះទេ ហើយលិខិតផ្ទេរនេះ គឺមានការបំពេញអក្សររួចរាល់ហើយ ខ្លួនគ្រាន់តែបញ្ជាក់ថាបានឃើញ តែប៉ុណ្ណោះ។ មូលហេតុដែលខ្លួនហ៊ានចុះហត្ថលេខា លើលិខិតផ្ទេរសិទ្ធរវាងឈ្មោះ [redacted] ស្រីនុច និងឈ្មោះ [redacted] ថាត ពីព្រោះឈ្មោះ [redacted] ស្រីនុច បានប្រាប់ខ្លួនថា ឯកសារផ្សេងៗត្រូវភ្លើងឆេះអស់អំឡុងពេលភ្លើងឆេះផ្សារ ម្យ៉ាងទៀតខ្លួនស្គាល់ច្បាស់អំពីទីតាំងដីនេះ ព្រោះស្ថិតនៅក្នុងភូមិ ដែលខ្លួនកាន់កាប់។

- សាក្សីឈ្មោះ [redacted] ដារ៉ា ឆ្លើយថា៖ ខ្លួនមិនបានដឹងថាប្រពន្ធរបស់ខ្លួន ទៅខ្ចីលុយពីឈ្មោះ ពេទ្យម៉ាប់ នោះទេ ហើយចំពោះស្នាមមេដៃក្នុងកិច្ចសន្យាខ្ចីប្រាក់នេះ ក៏មិនមែនជាស្នាមមេដៃរបស់ខ្លួនដែរ។ ខ្លួនមានដីនៅក្នុងភូមិព្ធត្រុំ ដីនេះខ្លួនទិញពីឈ្មោះ [redacted] ហេង ក្នុងឆ្នាំ២០០៨ តម្លៃ ប្រហែលជាង ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែខ្លួនដាក់តែឈ្មោះប្រពន្ធម្នាក់ ព្រោះខ្លួនមានដីច្រើនកន្លែង។ ខ្លួនមិនដឹងថាប្រពន្ធរបស់ខ្លួន កាត់ដីនៅភូមិព្ធត្រុំទៅឱ្យឈ្មោះ [redacted] មុំ ទេ ព្រោះខ្លួនរវល់នៅចំការ។ ចំណែកប្រពន្ធរបស់ខ្លួន យកដីនេះទៅលក់ឱ្យឈ្មោះ [redacted] ថាត ក៏ខ្លួនដឹងក្រោយពេលប្រពន្ធលក់រួចហើយ ទើបគាត់មកប្រាប់ថា លក់ដីនៅភូមិព្ធត្រុំ បានក្នុងមួយម៉ែត្រតម្លៃ ១០០ (មួយរយ) ដុល្លារអាមេរិក ហើយខ្លួនក៏មិនបានដឹងថា ប្រពន្ធរបស់ខ្លួន ផ្ទេរសិទ្ធឱ្យឈ្មោះ [redacted] មុំ ទៅខ្ចីពីធនាគារនោះទេ ។ ក្រោយពីទិញដីនៅភូមិព្ធត្រុំនោះហើយ ខ្លួនបានដាំបង្គោលថ្ម កម្ពស់០៣តឹកដែរ ប៉ុន្តែ



Scanned with CamScanner

ក្រោយៗមក ខ្លួនមិនដែលទៅមើលទៀតនោះទេ។ ខ្លួនមិនធ្លាប់ឃើញ លិខិតផ្ទេរសិទ្ធិរវាងឈ្មោះ [redacted] ស្រីនុច និងឈ្មោះ ប៊ុនថាត នោះទេ ព្រោះប្រពន្ធរបស់ខ្លួនលក់ដីនោះតែពីរនាក់ឈ្មោះ [redacted]ថាត តែប៉ុណ្ណោះ។

- អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា៖ ឈ្មោះ [redacted] ស្រីនុច បានផ្ទេរសិទ្ធិកាន់កាប់ដីនៅភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី គឺផ្តើមចេញពីកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ចំនួន ៣២.០០០.០០០ (សាមសិបពីរលាន) រៀល រវាងប្តីរបស់ខ្លួនឈ្មោះ [redacted] អេងលាង ហៅពេទ្យម៉ាប់ និងឈ្មោះ [redacted] ស្រីនុច និងប្តីឈ្មោះ [redacted] ដារ៉ា ដល់ពេលកំណត់ឈ្មោះ [redacted] ស្រីនុច មិនមានលទ្ធភាពសង ទើបគាត់កាត់ដីមកឱ្យខ្លួន។ នៅពេលដែលផ្ទេរសិទ្ធិកាន់កាប់ជាមួយឈ្មោះ [redacted] ស្រីនុច គឺធ្វើនៅផ្ទះលោកមេភូមិពូត្រុំ ឈ្មោះ [redacted] សាមិត និងបានយកទៅឱ្យចៅសង្កាត់រមនា ឈ្មោះ [redacted] គ្រើន ជួយបញ្ជាក់ដឹងឮដែរ។ ក្រោយពីទទួលបានសិទ្ធិកាន់កាប់ ខ្លួនធ្លាប់បានចូលទៅបោះបង្គោលចំនួន ០៤ដើម និងកាប់ឆ្ការព្រៃផងដែរ មានមេភូមិដឹងឮ។ លុះដល់ពេលខ្លួនរត់ឯកសារលក់ដីខាងលើ ទើបដឹងថាឈ្មោះ [redacted] ស្រីនុច បានលក់ដីឱ្យទៅអ្នកផ្សេងម្នាក់ទៀត។ ខ្លួនដឹងថាគេលក់ដីទំនាស់នេះ នៅឆ្នាំ២០១៩ តាមរយៈឈ្មោះ អាន (អ្នករត់ឯកសារលក់ដីឱ្យខ្លួន) នៅពេលខ្លួនទៅសួរដល់លោកចៅសង្កាត់រមនា ឈ្មោះ[redacted]ង្វក លោក ជ្រេង ធីល ( អតីតស្មៀនសង្កាត់រមនា) និងឈ្មោះ [redacted]ណារិន ក៏បានឆ្លើយថា ឈ្មោះ [redacted] ស្រីនុច លក់ឱ្យអ្នកផ្សេង។

- អំណានចម្លើយសាក្សីឈ្មោះ [redacted] អេងលាង បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] ស្រីនុច យូរដែលមកហើយ ស្គាល់តាមរយៈប្រពន្ធរបស់ខ្លួន ដោយការលេងតុងទីនជាមួយគ្នា។ ឈ្មោះ [redacted] ស្រីនុច ធ្លាប់មកខ្ចីលុយរបស់ខ្លួន កាលពីចុងឆ្នាំ២០១៤ ចំនួន ៣២.០០០.០០០ (សាមសិបពីរលាន) រៀល ដោយមិនបានធ្វើកិច្ចសន្យានោះទេ។ លុយនេះ គឺខ្លួនទៅដេញតុងទីននៅមន្ទីរពេទ្យបានចំនួន ៣២.០០០.០០០ (សាមសិបពីរលាន) រៀល រួចហើយយកទៅឱ្យឈ្មោះ [redacted] ស្រីនុច តែម្តង ដោយសន្យាថា និងសងលុយមកខ្លួនវិញក្នុងពេលឆាប់ៗ។ លុះពេលដែលខ្លួនទារលុយពីឈ្មោះ [redacted] ស្រីនុច ចេះតែគេចវេស ព្រមទាំងមិនលើកទូរសព្ទរបស់ខ្លួនទៀត ទើបនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ខ្លួនបានឱ្យឈ្មោះ [redacted] ស្រីនុច ធ្វើកិច្ចសន្យាខ្ចីប្រាក់ដោយឈ្មោះ[redacted] ស្រីនុច ជាអ្នកសរសេរផ្ទាល់ដៃ។ បន្ទាប់មកខ្លួនបានឱ្យឈ្មោះ[redacted] ស្រីនុច យកទៅឱ្យប្តីផ្តិតដែរ។ បន្ទាប់មកខ្លួន ឱ្យប្អូនថ្លៃរបស់ខ្លួនផ្តិតមេដៃជាសាក្សី ប៉ុន្តែមិនបានផ្តិតចំពោះមុខឈ្មោះ [redacted] ស្រីនុច ទេ រួចហើយខ្លួនក៏យកកិច្ចសន្យានេះ ទៅឱ្យមេភូមិ និងចៅសង្កាត់ប្រថាប់ត្រាដឹងឮ រួចហើយខ្លួនក៏រក្សាកិច្ចសន្យាទុកនៅខ្លួនឯង។ ខ្លួនចេះតែតាមទារលុយពីឈ្មោះ [redacted] ស្រីនុច ញឹកញាប់ពេក ទើបគាត់ថាមិនមានលុយសងហើយគាត់ថា គាត់មានដីមួយកន្លែងនៅភូមិពូត្រុំ ដូច្នេះគាត់សុំកាត់ដីមួយកន្លែងនេះមកឱ្យខ្លួន។ ខ្លួនរវល់នៅកន្លែងធ្វើការពេក ទើបខ្លួនឱ្យប្រពន្ធឈ្មោះ[redacted] មុំ ទៅផ្ទេរសិទ្ធិកាន់កាប់ជាមួយឈ្មោះ[redacted] ស្រីនុច។ ក្រោយពេលកាត់ផ្ទេរសិទ្ធិហើយ ប្លង់ដីនេះរក្សាទុកនៅឈ្មោះ [redacted] ស្រីនុច។ លុះដល់ពេលប្រពន្ធរបស់ខ្លួនមានរឿងក្តីក្តាំនៅស្នងការនគរបាល ទើបឈ្មោះ [redacted] ស្រីនុច បានកាន់ប្លង់នេះមកឱ្យខ្លួន ដើម្បីតម្កល់ទុកនៅស្នងការ

នគរបាល ទើបប្រពន្ធរបស់ខ្លួនបានត្រឡប់មកផ្ទះវិញ។ ខ្លួនតម្កល់ប្លង់ដីចំនួនពីរ ទី១.នៅភូមិពូត្រៃ ទី២. គឺប្លង់ដីដែលឈ្មោះ [redacted] ស្រីនុច ផ្ទេរមកឱ្យខ្លួន ដោយមានធ្វើកិច្ចសន្យាសងប្រាក់រវាងខ្លួន និងឈ្មោះ [redacted] សុផុន ឈ្មោះ [redacted] ឌីណា និងឈ្មោះ [redacted] រដ្ឋធានី ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ នៅចំពោះមុខស្នងការនគរបាល។ ក្រោយពេលខ្លួន កាន់កាប់ដីនៅភូមិពូត្រុំ រួចហើយ ខ្លួនក៏ធ្លាប់ចូលទៅកាន់កាប់ ដាំបង្គោលរបងថ្ម និងកាប់ឆ្ការព្រៃដែរ។ ខ្លួនក៏ធ្លាប់ទៅសួរពីមេឃុំរមនា អំពីម្ចាស់ដីដើមលក់ទៅឱ្យឈ្មោះ [redacted] ស្រីនុច ដោយគាត់ដឹងថាឈ្មោះ [redacted] ស្រីនុច កាត់ដីមកឱ្យខ្លួនដែរ។ ហើយខ្លួនក៏ធ្លាប់ប្រាប់បងប្អូនអំពីរឿងនេះដែរ។

- បានឃើញ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ១៧៦/០៨ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨។
- បានឃើញ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ០៥៩/១៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។
- បានឃើញ កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥។
- បានឃើញ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ៧០៧/០១៦ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦។
- បានឃើញ លិខិតមោឃៈ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ របស់ចៅសង្កាត់រមនា និងមេភូមិពូត្រុំ។
- បានឃើញ ពាក្យសុំមោឃៈភាព ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់ចៅសង្កាត់រមនា និងមេភូមិពូត្រុំ។

- **មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋានស្នើសុំ៖** តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនុច ពិតជាបានផ្ទេរកម្មសិទ្ធិដីឱ្យឈ្មោះ [redacted] មុំ តាមលិខិតលេខ ០៥៩/១៥ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ប្រាកដមែន។ ចម្លើយរបស់សាក្សីដែលបានធ្វើការដេញដោលបញ្ជាក់ថា ឈ្មោះ [redacted] ស្រីនុច បានផ្ទេរកម្មសិទ្ធដីដដែលឱ្យឈ្មោះ [redacted] ប៊ុនថាត និងឈ្មោះ [redacted] ថាវី ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ពិតជាបានភូតអាជ្ញាធរថាភ្លើងឆេះ ទើបគ្មានលិខិតបញ្ជាក់។ ម្យ៉ាងទៀតអាជ្ញាធរបានមោឃៈភាពនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ផងដែរ។ អាជ្ញាធរក៏បានដាក់ពាក្យទៅមន្ទីរដែនដី តាមលិខិតចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០២០។ ទង្វើនេះបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ស្រីនុច ពិតជាបានប្រព្រឹត្តអំពើលួចលក់អចលនវត្ថុរបស់អ្នកដទៃ និងបានធ្វើការភូតកុហក់អាជ្ញាធរ ដែលអំពើនេះជាអំពើផ្ទុយនឹងច្បាប់។ ដូច្នេះក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ និងទាមទារសំណងជម្ងឺចិត្តចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក។

- **តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ៖** ក្រោយពីស្ដាប់កិច្ចពិភាក្សាដេញដោលរួចមក ឃើញថា ជនជាប់ចោទបានសារភាពថាពិតជាបានផ្ទេរសិទ្ធិដីនៅភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ឱ្យឈ្មោះ [redacted] មុំ នៅឆ្នាំ២០១៥ ហើយខ្លួនបានផ្ទេរសិទ្ធិលើដីដដែលឱ្យឈ្មោះ [redacted] ប៊ុនថាត នៅឆ្នាំ២០១៨ ប៉ុន្តែដើម្បីគេចពីការបង់ពន្ធក៏សរសេរកាលបរិច្ឆេទនៅឆ្នាំ២០១៦ ដែលចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងការបញ្ជាក់របស់អាជ្ញាធរ។ ការផ្ទេរសិទ្ធិគឺធ្វើនៅឆ្នាំ២០១៨ ជនជាប់ចោទបានជួបអាជ្ញាធរ ដោយប្រាប់ថា លិខិតត្រូវឆេះ បាត់ឯកសារទើបអាជ្ញាធរពិនិត្យ និងបញ្ជាក់ផ្ទេរកម្មសិទ្ធិពីឈ្មោះ [redacted] ស្រីនុច ទៅឈ្មោះ



Scanned with CamScanner

[redacted] ប៊ុនថាត។ ទង្វើនេះសបញ្ជាក់ថា ជនជាប់ចោទពិតជាមានពិរុទ្ធភាពពីបទ លួចលក់អចលនវត្ថុរបស់អ្នកដទៃ និងបទសុំឱ្យផ្តល់ឯកសារដោយទុច្ចរិត ដូច្នេះតំណាងអយ្យការប្តឹងសុំរក្សាការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរដដែល។

- **មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានស្នើសុំ៖** ក្នុងអង្គហេតុកើតចេញពីកិច្ចសន្យាខ្ចីប្រាក់ទើបមានការផ្ទេរកម្មសិទ្ធិដីទៅឱ្យឈ្មោះ [redacted] មុំ។ ចំពោះកិច្ចសន្យាខ្ចីប្រាក់កូនក្តីខ្លួនពិតជាបានផ្តិតមេដៃមែន ប៉ុន្តែអក្សរសរសេរចំនួនទឹកប្រាក់ មិនមែនជារបស់កូនក្តីខ្លួនទេ ហើយចំនួនទឹកប្រាក់នេះគឺខុសទាំងស្រុង ដោយកូនក្តីខ្លួនទទួលស្គាល់តែ ៧.០០០.០០០ (ប្រាំពីរលាន) រៀលប៉ុណ្ណោះ ហើយកិច្ចសន្យានោះប្តីរបស់កូនក្តីខ្លួនមិនបានផ្តិតមេដៃទេ ដូច្នេះកិច្ចសន្យាមានវិការៈ ហើយក៏ស្នើសុំឱ្យធ្វើកោសលវិច័យដែរ ប៉ុន្តែពុំមានលទ្ធផល។ ចំពោះលិខិតផ្ទេរសិទ្ធិនៅឆ្នាំ២០១៥ កូនក្តីខ្លួនទទួលស្គាល់ថាបានផ្តិតមេដៃមែន ប៉ុន្តែក្នុងគោលបំណងឱ្យឈ្មោះ [redacted] មុំ ខ្ចីលុយពីធនាគារ មិនមែនទូទាត់បំណុលទេ។ ម្យ៉ាងទៀតការផ្ទេរសិទ្ធិក៏ពុំបានចុះពិនិត្យជាក់ស្តែងដែរ គឺគ្រាន់តែសរសេរតាមឯកសារដើម ដូច្នេះមិនអាចចោទប្រកាន់កូនក្តីខ្លួនបានទេ។ កូនក្តីខ្លួនជាម្ចាស់ពិតប្រាកដ ដូច្នេះស្នើសុំតុលាការលើកលែងចោទប្រកាន់។

- ជនជាប់ចោទនិយាយសម្តីចុងក្រោយ៖ ស្នើសុំតុលាការជួយរកយុត្តិធម៌ផង។

- ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល។

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ សេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានស្នើសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

- ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ។

- ក្រោយពីបានពិនិត្យឯកសារភស្តុតាងក្នុងសំណុំរឿងចប់សព្វគ្រប់។

## សំអាងហេតុ

១. តាមឯកសារបណ្តឹង និងឯកសារចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សី និងភស្តុតាងនានាក្នុងសំណុំរឿងបញ្ជាក់បានថា៖ កាលពីអំឡុងឆ្នាំ២០១៨ ស្ថិតនៅភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ពិតជាមានអង្គហេតុនៃបទល្មើស លួចលក់អចលនវត្ថុរបស់អ្នកដទៃ និងបទ សុំឱ្យផ្តល់ឯកសារដោយទុច្ចរិត ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ស្រីណុច ប្រាកដមែន ដោយជនជាប់ចោទបានផ្ទេរសិទ្ធិលើដីមានទីតាំងនៅភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ទៅឱ្យឈ្មោះ [redacted] មុំ តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីលេខ ០៥៩/១៥ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ហើយនៅឆ្នាំ២០១៨ ជនជាប់ចោទបានភូតកុហក់អាជ្ញាធរសង្កាត់រមនាថា *"ភ្លើងឆេះផ្ទះដែលនៅក្នុងផ្សារសែនមនោរម្យ ហើយបានឆេះឯកសារដីធ្លីទាំងអស់"* ដើម្បីឱ្យអាជ្ញាធរចេញលិខិតផ្ទេរសិទ្ធិកាន់កាប់ដីខាងលើ ឱ្យទៅបុគ្គលផ្សេង។

២. ជនជាប់ចោទបានឆ្លើយថា ខ្លួនទទួលស្គាល់ថាបានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិដីខាងលើឱ្យឈ្មោះ [redacted] មុំ ប្រាកដមែន ប៉ុន្តែក្នុងគោលបំណងខ្ចីប្រាក់ពីធនាគារប៉ុណ្ណោះ ប៉ុន្តែដោយខ្វះសាក្សីទើបធនាគារមិនយល់ព្រម។

នៅឆ្នាំ២០១៨ ខ្លួនបានលក់ដីនោះឱ្យទៅឈ្មោះ ថាត រស់នៅភ្នំពេញ ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ ដោយមានអាជ្ញាធរទទួលស្គាល់ ប៉ុន្តែខ្លួនមិនចាំថាបានប្រាប់អាជ្ញាធរអំពីការផ្ទេរកម្មសិទ្ធិឱ្យឈ្មោះ [redacted] មុំ ឬយ៉ាងណាទេ ហើយពេលធ្វើលិខិតផ្ទេរនោះ គឺខ្លួនបានភ្ជាប់ឯកសារប្លង់ចាស់ ដែលបានទិញពីឈ្មោះ [redacted] ហេង។ ចម្លើយនេះឃើញថា គ្រាន់តែជាការឆ្លើយដោះសារដើម្បីគេចវេសពីការទទួលខុសត្រូវប៉ុណ្ណោះ។ ផ្អែកតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីឈ្មោះ [redacted] អេងលាង បានបញ្ជាក់ថា ជនជាប់ចោទបានខ្ចីប្រាក់ពីខ្លួនចំនួន ៣២.០០០.០០០ (សាមសិបពីរលាន) រៀល។ ក្រោយពីខ្ចីប្រាក់រួច ជនជាប់ចោទតែងតែគេចវេស រហូតដល់ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ជនជាប់ចោទបានយល់ព្រមធ្វើកិច្ចសន្យាខ្ចីប្រាក់ ដោយគាត់ជាអ្នកសរសេរដោយផ្ទាល់ដៃ។ ក្រោយមកជនជាប់ចោទមិនមានលទ្ធភាពសងប្រាក់ ទើបសុខចិត្តផ្ទេរកម្មសិទ្ធិលើដីនៅភូមិពូត្រុំ សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី មកឱ្យខ្លួន។ ម្យ៉ាងវិញទៀត សាក្សីជាអាជ្ញាធរបានបញ្ជាក់ថា ជនជាប់ចោទបានអះអាងថា ភ្លើងឆេះផ្ទះហើយឆេះទាំងឯកសារដីធ្លី និងស្នើសុំឱ្យអាជ្ញាធរធ្វើលិខិតផ្ទេរសិទ្ធិពីឈ្មោះ [redacted] ស្រីនុច ឱ្យឈ្មោះ [redacted] ថាត។

៣. អំពើរបស់ជនជាប់ចោទ ដែលបានផ្ទេរកម្មសិទ្ធិលើដីឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ហើយក្រោយមកបានផ្ទេរកម្មសិទ្ធិលើដីដដែលនេះទៅឱ្យតតិយជន គឺជាបទល្មើស លួចលក់អចលនវត្ថុរបស់អ្នកដទៃ ដែលច្បាប់បញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល។ ទន្ទឹមនឹងនោះ ជនជាប់ចោទបានភូតកុហក់អាជ្ញាធរសាធារណៈ ដោយទុច្ចរិត ដើម្បីទទួលបានការយល់ព្រម ធ្វើលិខិតផ្ទេរកម្មសិទ្ធិឱ្យតតិយជន គឺជាបទល្មើស សុំឱ្យផ្តល់ឯកសារដោយទុច្ចរិត តាមបញ្ញត្តិមាត្រា៧៣២ នៃក្រមព្រហ្មទណ្ឌ។

៤. ជនជាប់ចោទ ជានីតិជន មាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយ ដែលនាំឱ្យមានមន្ទិលសង្ស័យថាជននេះមានបញ្ហាវិកលស្មារតីក្នុងពេលប្រព្រឹត្តល្មើសឡើយ។ ជនជាប់ចោទជាសមត្ថជន ដែលមានការពិចារណា ព្រមទាំងយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។

៥. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរ ទុកជាបានការដដែល។ ទន្ទឹមនឹងនោះ មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ តុលាការយល់ឃើញថាការប្តឹងសុំ និងការស្នើសុំនេះមានលក្ខណៈត្រឹមត្រូវ ដែលអាចឱ្យតុលាការពិចារណាតាមច្បាប់។

៦. មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានស្នើសុំឱ្យតុលាការលើកលែងចោទប្រកាន់លើកូនក្តីខ្លួន តុលាការយល់ឃើញថា ពុំមានភាពត្រឹមត្រូវឡើយ ដោយហេតុថា ជនជាប់ចោទបានទទួលស្គាល់ថាខ្លួនបានផ្តិតមេដៃផ្ទេរកម្មសិទ្ធិដីខាងលើឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុំ នៅឆ្នាំ២០១៥ ហើយនៅឆ្នាំ២០១៨ ក៏បានផ្ទេរឱ្យតតិយជនម្តងទៀត ដោយក្នុងនោះជនជាប់ចោទបានភូតកុហក់អាជ្ញាធរសាធារណៈទៀតផង។



Scanned with CamScanner

៧. មានធាតុផ្សំបទល្មើស និងមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ពីបទ៖ លួចលក់អចលនវត្ថុរបស់អ្នកដទៃ និងបទ សុំឱ្យផ្តល់ឯកសារដោយទុច្ចរិត ប្រព្រឹត្តនៅសង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៥៥ នៃច្បាប់ភូមិបាល និងមាត្រា៦៣២ នៃក្រមព្រហ្មទណ្ឌ។

៨. ដើមបណ្តឹងរដ្ឋប្បវេណី ទាមទារសំណងរដ្ឋប្បវេណីចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក តុលាការនឹងធ្វើការពិចារណាទៅតាមច្បាប់។

៩. ជនជាប់ចោទបានចូលបង្ហាញខ្លួននាពេលសវនាការ តាមមាត្រា៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ម្យ៉ាងទៀត ដើមបណ្តឹងរដ្ឋប្បវេណី មិនបានចូលបង្ហាញខ្លួននាពេលសវនាការទេ ប៉ុន្តែមានមេធាវីតំណាងដោយត្រឹមត្រូវ តាមមាត្រា៣៦៣ កថាខណ្ឌទី១ ដូច្នេះសាលក្រមនេះ ជាសាលក្រមចំពោះមុខ។

## សេចក្តីសម្រេច

១. ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ស្រីនុច ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ២(ពីរ)ឆ្នាំ ពីបទ **លួចលក់អចលនវត្ថុរបស់អ្នកដទៃ និងបទ សុំឱ្យផ្តល់ឯកសារដោយទុច្ចរិត** ប្រព្រឹត្តនៅសង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីអំឡុងឆ្នាំ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៥៥ នៃច្បាប់ភូមិបាល និងមាត្រា៦៣២ នៃក្រមព្រហ្មទណ្ឌ។

២. បង្គាប់ឱ្យជនជាប់ចោទ ជួសជុលព្យសនកម្ម តាមរយៈការសងសំណងរដ្ឋប្បវេណីចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ទៅដើមបណ្តឹងរដ្ឋប្បវេណី។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា៖ [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា៖ [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ ពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
មណ្ឌលគិរី,ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner